ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៥៦/១៨-ដាប់ប៊ីលយូ អែនដ៍ ឌី (កម្ពុជា) ខូ អិលធីឌី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **យូ សួនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គីមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ដាប់ប៊ីលយូ អែនដ៍ ឌី (កម្ពុជា) ខូ អិលធីឌី**

អាសយដ្ឋាន ៖ ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៥៧ ០៩ ៧៦ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

| | | |
|---|---|---|
| ១- | លោក តាំង ម៉េង | មេធាវី |
| ២- | លោកស្រី មាស សារ៉េត | ប្រធានផ្នែករដ្ឋបាល |
| ៣- | លោកស្រី ឆេង គន្ធា | ជំនួយការផ្នែករដ្ឋបាល |
| ៤- | លោក លៀង ភារៈ | តុកាត់ |
| ៥- | លោក ស៊ាន សារុន | ជាងភ្លើង |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ដាប់ប៊ីលយូ អែនដ៍ ឌី (កម្ពុជា) ខូ អិលធីឌី**

អាសយដ្ឋាន ៖ ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩៦ ៨៨០ ៨៥ ០០ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖

| | |
|---|---|
| ១- លោក ឃុន គម | សហជីព |
| ២- លោក សឿង ប្រុស | ប្រតិភូបុគ្គលិក |
| ៣- លោក នួច ចាន់ឌី | សហជីព |
| ៤- លោក វិត វណ្ណ | ប្រតិភូបុគ្គលិក |
| ៥- លោក ស៊ឹម បូរី | ប្រតិភូបុគ្គលិក |
| ៦- លោក ប៊ុន សំណាល់ | ប្រតិភូបុគ្គលិក |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់បំណាច់អតីតភាពការងារ (បើកផ្តាច់) សរុបទាំងអស់ ដល់ពួកគាត់ត្រឹមថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ ដោយទូទាត់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍បន្ទាប់បន្សំរួមបញ្ចូលគ្នា។ ដោយឡែក ភាគីនិយោជកផ្តល់ប្រាក់បំណាច់អតីតភាពការងារសរុបទាំងអស់ជូនពួកគាត់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ ហើយរបៀបនៃការទូទាត់ គឺអនុវត្តតាមសេចក្តីប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ៤៤៣ កប/ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨។

២- ភាគីកម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនគណនាប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ ដូចគ្នាទៅនឹងឆ្នាំ២០១៩ ផងដែរ។

៣- ភាគីកម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ នៅដដែលក្នុងអំឡុងពេលនៃការផ្ទេរកូដកម្ម។

សូមបញ្ជាក់ថា: ចំពោះចំណុចទាមទារទី២ និងទី៣ អ្នកផ្សះផ្សានៅបន្តដោះស្រាយជាមួយក្រុមប្រឹក្សាចរចា តែពួកគាត់មិនបន្តរកដំណោះស្រាយតទៅទៀតទេ (ដោយសារការដោះស្រាយនូវចំណុចទី១ ពុំសះជានឹងគ្នា) ដូច្នេះ ពួកគាត់ដើរចេញពីតុចរចារ ហើយមិនព្រមចុះហត្ថលេខាលើកំណត់ហេតុផ្សះផ្សានោះទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃ

THE ARBITRATION COUNCIL

ប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ដាប់ប៊ិលយូ អែនដ៍ ឌី (កម្ពុជា) ខូ អិលធីឌី លេខ ១១៨៧ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងជួបប្រជុំមុនសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

កាលបរិច្ឆេទប្រជុំមុនសវនាការ ៖ ថ្ងៃព្រហស្បតិ៍ ១២រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១០ និង ០០ នាទី ព្រឹក ។

បញ្ហានីតិវិធី៖

នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ដាប់ប៊ិលយូ អែនដ៍ ឌី (កម្ពុជា) ស្តីពីការធ្វើកូដកម្មទាមទារនូវលក្ខខណ្ឌការងារ ចំនួន ៣ ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាវិវាទ ចំនួន ៣ ចំណុចនេះ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជា ចំនួន ៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ដាប់ប៊ិលយូ អែនដ៍ ឌី (កម្ពុជា) លេខ ១១៨៧ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ នៅមុនពេលក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលលិខិតមួយច្បាប់ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រុមហ៊ុន ដាប់ប៊ិលយូ អែនដ៍ ឌី (កម្ពុជា) ដែលមានកម្មវត្ថុ សំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ដាប់ប៊ិលយូ អែនដ៍ ឌី (កម្ពុជា)។ ហេតុនេះ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា លេខ ០០៧/១៨ កបអ. ឱ្យផ្អាកជាបន្ទាន់ នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ដាប់ប៊ិលយូ អែនដ៍ ឌី (កម្ពុជា) រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ តទៅ តាមវេនរបស់ខ្លួន។

បន្ទាប់ពីចេញសេចក្តីបញ្ជានេះមក នៅរសៀលថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងពីភាគីនិយោជក និងកម្មករនិយោជិត តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលថា កម្មករ

និយោជិតមិនបានត្រឡប់ចូលធ្វើការតាមសេចក្ដីបញ្ជានោះទេ ហើយនៅតែបន្តធ្វើកូដកម្មដដែល។ ហេតុនេះ ក្រុម-ប្រឹក្សាអាជ្ញាកណ្ដាល បានអញ្ជើញភាគីពាក់ព័ន្ធមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១០ និង ០០ នាទី ព្រឹក។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល ភាគីនិយោជក និងភាគីកម្មករនិយោជិត មានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល ភាគីកម្មករនិយោជិតបានលើកឡើងថា តំណាងភាគីកម្មករនិយោជិតបានព្យាយាមពន្យល់ប្រាប់ពីនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលដល់កម្មករនិយោជិតដែលធ្វើកូដកម្ម និងបានប្រាប់ពួកគាត់ឱ្យចូលធ្វើការងារវិញតាមសេចក្ដីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ប៉ុន្តែ ពួកគាត់មិនព្រមចូលធ្វើការវិញនោះទេ ហើយក៏មិនស្ដាប់តាមការណែនាំរបស់តំណាងភាគីកម្មករនិយោជិតដែរ។ សរុបមក មកដល់ពេលបច្ចុប្បន្ននេះ ភាគីទាំងពីរទទួលស្គាល់ថា កម្មករនិយោជិតប្រមាណជា ១៨០០ នាក់ នៅតែបន្តធ្វើកូដកម្មដដែល។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតរបស់ក្រុមហ៊ុន W & D (Cambodia) Co., Ltd គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពី សំណើសុំចេញសេចក្ដីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន W & D (Cambodia) Co., Ltd ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

១- របាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ដាប់ប៊ីលយូ អែនដ៍ ឌី (កម្ពុជា) ខូ អិលធីឌី លេខ ១១៨៧ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ដាប់ប៊ីលយូ អែនដ៍ ឌី (កម្ពុជា) ខូ អិលធីឌី ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ដាប់ប៊ីលយូ អែនដ៍ ឌី (កម្ពុជា) ខូ អិលធីឌី ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ របស់នាយកដ្ឋានវិវាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល

១- លិខិតលេខ ៣៤១ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ជម្រាបមក លោក-លោកស្រីតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ដាប់ប៊ីលយូ អែនដ៍ ឌី (កម្ពុជា) ស្ដីពីការជ្រើសអាជ្ញាកណ្ដាល។

THE ARBITRATION COUNCIL

២- កំណត់ហេតុស្ដីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្ដាល ពីបញ្ជីឈ្មោះអាជ្ញាកណ្ដាលស្នើដោយសហជីព កម្មករនិយោជិត ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

៣- សេចក្ដីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល លេខ០០៧/១៨កបអ. ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្ដល់ព័ត៌មាន លេខ ០០៩ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១១រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩។

៥- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្ដល់ព័ត៌មាន លេខ ០១០ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១១រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩។

**អង្គហេតុ ៖**

មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនបានដំណើរការសវនាការ។

**ហេតុផលនៃសេចក្ដីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្ដាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលចែងថា៖ "*ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្ដាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្ដីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្ដាលបានអញ្ជើញឱ្យចូលរួម* "។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្ដាល។

នៅក្នុងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយប្រការនេះថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងមិនបន្តដំណើរការអាជ្ញាកណ្ដាលទេ នៅពេលណាកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (*សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ៥៩/០៦-សាង វ៉, លេខ ៣៩/០៨-ចុង យ៉ូវ, លេខ ១៣៧/០៩ &១៣៨/០៩-ញ៉ូ ភាញ់, លេខ ១១០/១១-ស៊ីម៉ាណូ, លេខ ១០៤/១៣-សាប្រីណា (ខេមបូឌា), លេខ ៣២៧/១៤-ជីមលី (ខេមបូឌា) ភីធីអ៊ី អិលធីឌី, លេខ ០៧១/១៥-អ៊ីម វ៉េ កាត់ដេរ អន្តរជាតិ សាខាកំពង់ឆ្នាំង និងលេខ ០២១/១៦-ស្ការឡែថ៍ អីភែរីល មេនូហ្វេកធីរីង)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះ ក៏យល់ស្របទទួលយកហេតុផល និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងខាងលើដែរ។

THE ARBITRATION COUNCIL

នៅក្នុងសំណុំរឿងនេះ នៅក្នុងនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភាគីកម្មករនិយោជិតបាននិងកំពុងតែធ្វើកូដកម្ម ហើយក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទទួលសំណើពីតំណាងនិយោជកឱ្យចេញសេចក្ដីបញ្ជា ដើម្បីផ្អាកកូដកម្មរបស់កម្មករនិយោជិត។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជា លេខ ០០៧/១៨ កបអ. ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨ ឱ្យកម្មករនិយោជិតបញ្ឈប់កូដកម្ម និងចូលធ្វើការធម្មតា និងបានអញ្ជើញភាគីទាំងពីរមកចូលរួមកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ ដើម្បីសួរបញ្ជាក់ពីករណីកូដកម្មនេះ។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល ភាគីកម្មករនិយោជិតបានលើកឡើងថា មកដល់ថ្ងៃនេះ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មដដែល ទោះបីជាមានការពន្យល់ណែនាំពីតំណាងភាគីកម្មករនិយោជិត ដើម្បីឱ្យកម្មករនិយោជិតចូលធ្វើការវិញក៏ដោយ។ ករណីនេះ ភាគីទាំងពីរទទួលស្គាល់ថា កម្មករនិយោជិតប្រមាណជា ១៨០០ នាក់ នៅតែបន្តធ្វើកូដកម្ម ដោយមិនព្រមចូលធ្វើការងារវិញតាមសេចក្ដីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។

ហេតុនេះ យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល សម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចសេចក្ដីដូចតទៅ៖

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងលេខ ០៥៦/១៨-ដាប់ប៊ឺលយូ អេនដ៍ ឌី (កម្ពុជា) ខូ អិលធីឌី។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក**

ឈ្មោះ៖ **យូ សួនធី**

ហត្ថលេខា៖ ----------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

ឈ្មោះ៖ **ស៊ីន គឹមស៊ាន**

ហត្ថលេខា៖ ----------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល**

ឈ្មោះ៖ **ម៉ែន ប៊ុនឈា**

ហត្ថលេខា៖ ----------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល THE ARBITRATION COUNCIL